ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៦ សសរ

3272
26 02 99

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការគ្រប់គ្រងផ្នែកទាំងបីនៃកម្មសិទ្ធិបញ្ញា

* * * * *

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងកិច្ចព្រមព្រៀង ស្តីពីទំនាក់ទំនងពាណិជ្ជកម្ម និង កម្មសិទ្ធិបញ្ញា រវាងព្រះរាជាណាចក្រកម្ពុជា និង សហរដ្ឋអាមេរិក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៦

-យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-យោងតាមស្មារតីអង្គប្រជុំអន្តរក្រសួង នាថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

## សម្រេច

**ប្រការ១** : ត្រូវបានបង្កើតគណៈកម្មការគ្រប់គ្រងផ្នែកទាំងបី នៃកម្មសិទ្ធិបញ្ញា ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| -ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម | ប្រធាន |
| -ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល | អនុប្រធាន |
| -ឯកឧត្តម តំណាង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| -ឯកឧត្តម តំណាង ក្រសួងពត៌មាន | សមាជិក |

**ប្រការ២** : គណៈកម្មការគ្រប់គ្រងផ្នែកទាំងបី នៃកម្មសិទ្ធិបញ្ញា មានភារកិច្ចដូចតទៅ ៖

-ជំរុញការរៀបចំសេចក្តីព្រាងច្បាប់នានា ដែលពាក់ព័ន្ធទៅនឹងការអនុវត្តកិច្ចព្រមព្រៀង ស្តីពីទំនាក់ទំនងពាណិជ្ជកម្ម និង កម្មសិទ្ធបញ្ញា រវាងព្រះរាជាណាចក្រកម្ពុជា និង សហរដ្ឋអាមេរិក និងកិច្ចព្រមព្រៀងនានា រវាងព្រះរាជាណាចក្រកម្ពុជា និង បណ្តាប្រទេសនៃសមាគមអាស៊ាន ។

-សំរបសំរួលអោយមានភាពរលូនលើរាល់ការងារ ដែលទាក់ទិនដល់កម្មសិទ្ធិបញ្ញា រវាងក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងពត៌មាន និង ក្រសួងស្ថាប័នផ្សេងៗទៀត ដែលមានការពាក់ព័ន្ធ ។

-សំរបសំរួល និង ទទួលជំនួយនានាពីសហគមន៍អន្តរជាតិ លើវិស័យកម្មសិទ្ធិបញ្ញា ។

-ធ្វើរបាយការណ៍អំពីលទ្ធផលការងារ ជូនរាជរដ្ឋាភិបាល តាមតំណាក់ការនីមួយៗ ។

ប្រការ៣ : គណៈកម្មការនេះ មានលេខាធិការដ្ឋានមួយ សំរាប់ជួយការងារដែលមានសមាសភាពដូចខាងក្រោម :

- ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា ប្រធាន
- តំណាង ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល សមាជិក
- តំណាង ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- តំណាង ក្រសួង ពត៌មាន សមាជិក

លេខាធិការដ្ឋាននេះ មានទីតាំង និងប្រើប្រាស់មន្ត្រីជំនួយការមួយចំនួនទៀត តាមការចាំបាច់ នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ។

ប្រការ៤ : សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន

- គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម ដើម្បីសំរួលការងារ ។

ប្រការ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែនិងថាមពល រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ឯកឧត្តម អស់លោក ដែលមានចែងក្នុងប្រការ១ និង ប្រការ៣ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

កន្លែងទទួល :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- កាលប្បវត្តិ-ឯកសារ

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

លេខ : ៣៣ ពណ.របចល

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងបញ្ជូនមក

- ថ្នាក់ដឹកនាំ " ជូនជ្រាប "
- អគ្គនាយកបច្ចេកទេស
- នាយកដ្ឋាន កម្មសិទ្ធបញ្ញា √ " ជាពត៌មាន "
- ឯកសារ

ភ្នំពេញ,ថ្ងៃទី ១៧ ខែ ៣ ឆ្នាំ ១៩៩៩

ប្រធាននាយកដ្ឋានរដ្ឋបាល